**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារជាន់ខ្ពស់ដើម្បីដឹកនាំសំរបសំរួល និង រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ។
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## ស ំ រ េ ច

**មាត្រា ១ :** បង្កើតក្រុមការងារជាន់ខ្ពស់មួយ ដើម្បីដឹកនាំសំរបសំរួលការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (ICT) ។

ក្រុមការងារជាន់ខ្ពស់ មានភារកិច្ចពិភាក្សាពិគ្រោះយោបល់ និងសំរបសំរួលជាមួយស្ថាប័នផ្តល់ជំនួយ ស្ថានទូតនានាប្រចាំនៅកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអប់រំ ដើម្បីរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រជាតិ ឯកសារជាតិជាផ្លូវការស្តីពីការប្រើប្រាស់ ICT ដូចជា :

ស្ល

- ពិនិត្យ ខ្លឹមសារសេចក្តីព្រាងឯកសាររបស់ក្រុមការងារបច្ចេកទេសនិមួយៗ ។
- កំណត់ចំនួនអ្នកស្រាវជ្រាវជាតិដើម្បីធ្វើសេចក្តីព្រាងឯកសារសំរាប់សិក្សាលើវិស័យ ICT របស់ក្រុមការងារបច្ចេកទេសនិមួយៗ ។
- ផ្តល់ការណែនាំជារួមដល់ការស្រាវជ្រាវរបស់ក្រុមការងារបច្ចេកទេស ដើម្បីរៀបចំឯកសារដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ជាតិ ។
- ធានាថា កិច្ចប្រជុំកំពូលស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រ និងកិច្ចពិគ្រោះយោបល់ជាតិស្របតាមកម្មវត្ថុនៃគំរោង ។
- ពិនិត្យលើការរៀបចំឯកសារចុងក្រោយស្តីពីគោលនយោបាយ ។
- ជួយ និងផ្តល់ការណែនាំអំពីវិធីបញ្ចូលឯកសារចុងក្រោយស្តីពីគោលនយោបាយទៅក្នុងអនុក្រឹត្យ ស្របតាមនីតិវិធីចាំបាច់របស់ជាតិ ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា ។
- ធានាថា សន្និសីទជាតិមួយត្រូវបានរៀបចំឡើងដើម្បីលាតត្រដាងពត៌មានអំពីឯកសារចុងក្រោយស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រតាមបណ្តាញអេឡិចត្រូនិច ។

**មាត្រា ២** : សមាសភាពក្រុមការងារជាន់ខ្ពស់រួមមាន :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម | លោកជំទាវរដ្ឋមន្ត្រី | ឬរដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ | សមាជិក |
| ៣- ឯកឧត្តម | **សឺន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម | **ពិត ចំណាន** | សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៥- ឯកឧត្តម | **ភូ លឺវុឌ្ឍ** | អគ្គលេខាធិការ NiDA | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ៣** : សមាជិកអចិន្ត្រៃយ៍មានភារកិច្ចសំរបសំរួលការងារទូទៅរវាងក្រុមការងារជាន់ខ្ពស់ និង ក្រុមការងារបច្ចេកទេសដែលនឹងត្រូវបង្កើតឡើងដោយប្រកាសមួយដាច់ដោយឡែក ។

**មាត្រា ៤** : ក្នុងករណីចាំបាច់ ប្រធានក្រុមការងារជាន់ខ្ពស់អាចលើកសំណើបំពេញបន្ថែមសមាជិករបស់ខ្លួនតាមតំរូវការជាក់ស្តែង ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិកក្រុមការងារជាន់ខ្ពស់ ដូចមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័ន*
- *ឯកសារ-កាលប្បវត្តិ*